# Family Tax Benefit (ប្រាក់ឧបត្ថម្ភពន្ធដារសម្រាប់ជួយគ្រួសារ)

Family Tax Benefit គឺជាការបង់ប្រាក់ជាពីរផ្នែកដែលជួយបង់ថ្លៃការចិញ្ចឹមកូន។

Family Tax Benefit Part A (ប្រាក់ឧបត្ថម្ភពន្ធដារសម្រាប់ជួយគ្រួសារផ្នែក “**ក**”) ត្រូវបានបើកជូនសម្រាប់កូននីមួយៗ។ ចំនួនប្រាក់ឧបត្ថម្ភដែលអ្នកទទួលបានគឺអាស្រ័យទៅលើស្ថានភាពគ្រួសាររបស់អ្នក។ ប្រសិនបើកូនស្ថិតក្រោមការថែទាំរបស់អ្នក មុនពេលវាមានអាយុមួយឆ្នាំ ឬក៏អ្នកសុំកូនមកចិញ្ចឹមមានអាយុប៉ុន្មានក៏ដោយ អ្នកអាចទទួលបាននូវការតម្លើងប្រាក់ឧបត្ថម្ភលើ Family Tax Benefit Part A ។ ប្រាក់ឧបត្ថម្ភបៀបនេះគេហៅថា Newborn Upfront Payment (ប្រាក់ឧបត្ថម្ភភ្លាមនៅពេលកូនកើត) និង Newborn Supplement (ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កូនទើបកើត) ។

Family Tax Benefit Part B (ប្រាក់ឧបត្ថម្ភពន្ធដារសម្រាប់ជួយគ្រួសារផ្នែក “**ខ**”) ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមទៅដល់ម្តាយ ឬឪពុកទោល អ្នកថែទាំដែលមិនមែនជាឪពុកម្តាយ (ដោយរាប់បញ្ចូលទាំងជីដូនជីតា) និងគូស្រករដោយមានម្នាក់រកប្រាក់ចំណូលចម្បង។ ការសុំប្រាក់ឧបត្ថម្ភរបស់អ្នកនឹងត្រូវឆ្លងកាត់ការធ្វើតេស្តលើប្រាក់ចំណូល ហើយនិងចំនួនប្រាក់ឧបត្ថម្ភដែលអ្នកទទួលបាននឹងអាស្រ័យទៅលើអាយុកូនក្មេងជាងគេបង្អស់របស់អ្នក។

នៅក្នុងស្ថានភាពខ្លះ អ្នកអាចចែករំលែកការថែទាំកូន។ ប្រសិនបើអ្នកស្ថិតក្នុងស្ថានភាពនេះ អ្នកអាចនៅតែទទួលបាន Family Tax Benefit ខ្លះសម្រាប់កូន ប្រសិនបើអ្នកថែទាំកូនបានយ៉ាងតិចបំផុត 35ភាគរយនៃពេលវេលាត្រូវថែទាំកូន។

## សិទ្ធិទទួលបាន

### Family Tax Benefit Part A

អ្នកអាចមានសិទ្ធិទទួលបាន Family Tax Benefit Part A ប្រសិនបើអ្នកថែទាំកូនក្នុងបន្ទុកដែល៖

- មានអាយុតិចជាង 15ឆ្នាំ ឬ
- មានអាយុ 16 ដល់ 19ឆ្នាំ ហើយនិង
  - កំពុងសិក្សាពេញម៉ោងនៅក្នុងវគ្គសិក្សាដែលមានការអនុញ្ញាតត្រឹមត្រូវដែលឈានទៅបញ្ចប់ថ្នាក់ទី12 ឬសញ្ញាប័ត្រស្មើដោយមានបន្ទុក ការសិក្សាដែលអាចទទួលយកបាន ឬ
  - បានទទួលការលើកលែងពីលក្ខខណ្ឌតម្រូវឲ្យសិក្សា។

ប្រសិនបើអ្នកមានសិទ្ធិទទួលបាន Family Tax Benefit Part A សម្រាប់កូនក្នុងបន្ទុកដែលមានអាយុ 16 ដល់ 19ឆ្នាំ អ្នកអាចទទួលបានប្រាក់ឧបត្ថម្ភរហូតដល់ដំណាច់ឆ្នាំតាមប្រតិទិនដែលវាឈានចូលអាយុ 19ឆ្នាំ ប្រសិនបើវានៅបន្តការសិក្សាពេញម៉ោងនៅតាមសាលាមធ្យមសិក្សា។

### Family Tax Benefit Part B

ប្រសិនបើអ្នកជាគូស្រករម្នាក់ អ្នកអាចមានសិទ្ធិទទួលបាន Family Tax Benefit Part B ប្រសិនបើអ្នកថែទាំកូនក្នុងបន្ទុកដែលមានអាយុតិចជាង 13ឆ្នាំ។

ប្រសិនបើអ្នកជាម្តាយ ឬឪពុកទោល ជីដូន ឬជីតា ឬជីដូនទួត ឬជីតាទួតដែលថែទាំកូន ឬចៅ អ្នកអាចមានសិទ្ធិទទួលបាន Family Tax Benefit Part B ប្រសិនបើអ្នកថែទាំកូន ឬចៅដែល៖

- មានអាយុតិចជាង 16ឆ្នាំ ឬ
- ជាសិស្សមធ្យមសិក្សាពេញម៉ោងរហូតដល់ដំណាច់ឆ្នាំតាមប្រតិទិនដែលវាមានអាយុឈានចូល 18ឆ្នាំ។

ការអប់រំនៅតាមផ្ទះសម្រាប់កូនអាយុ 16 ដល់ 19ឆ្នាំ មិនបំពេញទៅតាមលក្ខខណ្ឌតម្រូវការសិក្សាសម្រាប់ទទួលបាន Family Tax Benefit ទេ។

**លក្ខខណ្ឌតម្រូវការចាក់វ៉ាក់សាំងបង្ការ**
ឆ្នាំ2017-18 គឺលក្ខខណ្ឌតម្រូវឲ្យមានការចាក់វ៉ាក់សាំងបង្ការឆ្នាំចុងក្រោយដែលភ្ជាប់ជាមួយនឹងប្រាក់ឧបត្ថម្ភបន្ថែមនៃ Family Tax Benefit Part A។

ចាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2018 តទៅ ប្រសិនកូនរបស់អ្នកមិនបានចាក់វ៉ាក់សាំងបង្ការតាមលក្ខខណ្ឌតម្រូវការទេ យើងអាចកាត់បន្ថយអត្រា Family Tax Benefit Part A របស់អ្នក។

**ប្រសិនបើអ្នកកំពុងទទួលបាន Family Tax Benefit Part A ហើយនិងប្រាក់ឧបត្ថម្ភលើប្រាក់ចំណូល**
អ្នកត្រូវធានាថាកូននីមួយៗដែលអ្នកកំពុងទទួលបាន Family Tax Benefit Part A ពីពួកគេមានការពិនិត្យ សុខភាព ប្រសិនបើពួកគេមានអាយុឈានចូលដល់បួនឆ្នាំនៅ ឬបន្ទាប់ពីថ្ងៃទី1 ខែកក្កដា ឆ្នាំ 2018។ អ្នក ត្រូវប្រាប់យើង នៅពេលបានពិនិត្យសុខភាពចប់សព្វគ្រប់ភ្លាម។ ការពិនិត្យសុខភាពនេះត្រូវធ្វើឡើងឲ្យ ចប់សព្វគ្រប់នៅមុនពេលខួបកំណើតប្រាំឆ្នាំរបស់កូនអ្នក។ ប្រសិនបើអ្នកមិនប្រាប់យើងទេ យើងអាចកាត់ បន្ថយប្រាក់ឧបត្ថម្ភ Family Tax Benefit Part A របស់អ្នក។

យើងអាចកាត់បន្ថយប្រាក់ឧបត្ថម្ភរបស់អ្នករហូតដល់ទៅដល់ 52សប្តាហ៍។ ការកាត់នេះគឺផ្អែកទៅលើរយៈពេលដែលអ្នកបានទទួល Family Tax Benefit Part A ហើយនិងអ្នក ឬក៏ដៃគូរបស់អ្នកបានទទួលប្រាក់ឧបត្ថម្ភលើប្រាក់ចំណូល។

# លក្ខខណ្ឌតម្រូវការតាំងលំនៅ

ដើម្បីឲ្យអាចមានសិទ្ធិទទួលបាន Family Tax Benefit Part A និង Part B  អ្នកត្រូវតែឆ្លើយតបទៅតាមលក្ខខណ្ឌតម្រូវការតាំងលំនៅនានា។

អ្នកត្រូវតែកំពុងរស់នៅប្រទេសអូស្ត្រាលី ហើយនិង៖
- មានសញ្ជាតិអូស្ត្រាលី
- កាន់ទិដ្ឋាការតាំងលំនៅអចិន្ត្រៃយ៍
- កាន់ Special Category Visa (ទិដ្ឋាការប្រភេទពិសេស) ឬ
- កាន់ប្រភេទទិដ្ឋាការបណ្តោះអាសន្នខ្លះ ឧទាហរណ៍ដូចជាទិដ្ឋាការ Partner Provisional (ដៃគូបណ្តោះអាសន្ន) ឬក៏ទិដ្ឋាការ Temporary Protection (ការពារបណ្តោះអាសន្ន)។

កូនរបស់អ្នកក៏ត្រូវតែឆ្លើយទៅតាមលក្ខខណ្ឌតម្រូវការតាំងលំនៅនានាដែរ ឬកំពុងរស់នៅជាមួយអ្នក ហើយអ្នកត្រូវតែបន្តឆ្លើយតបទៅតាមលក្ខខណ្ឌតម្រូវការតាំងលំនៅនានាសម្រាប់រយៈពេលដែលអ្នកទទួលបានប្រាក់ឧបត្ថម្ភនេះ។

ប្រសិនបើទិដ្ឋាការតាំងលំនៅអចិន្ត្រៃយ៍បានផ្តល់នៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2019 អ្នកត្រូវតែរស់នៅ និងតាំងលំនៅប្រទេសអូស្ត្រាលីក្នុងអំឡុងពេលមួយ ឬអំឡុងពេលនានាដែលសរុបមានរយៈពេលយ៉ាងហោចណាស់មួយឆ្នាំ មុនពេលដែលអ្នកអាចទទួលបាន Family Tax Benefit Part A។

អ្នកមិនបាច់ត្រូវបំពេញលក្ខខណ្ឌ Newly Arrived Resident’s Waiting Period ប្រសិនបើអ្នក៖
- ជាជនជាតិអូស្ត្រាលី ឬ
- បានមកដល់ដោយមានលិខិតឆ្លងដែនញូវ៉ែលហ្ស៊ីឡង់ (ឧទាហរណ៍ បានកាន់ ឬកាន់ Special Category visa) ឬ
- ជាជនភៀសខ្លួន ឬអតីអជនភៀសខ្លួន ឬ
- កាន់ ឬកាលមុនបានកាន់ថ្នាក់រងនៃទិដ្ឋាការជាក់លាក់ណាមួយ ឬ
- ជាដៃគូរបស់ជនភៀសខ្លួន អតីតជនភៀសខ្លួន ឬជនអន្តោប្រវេសន៍មនុស្សធម៌ ហើយបានធ្វើជាដៃគូនៃមនុស្សនោះនៅពេលដែលពួកគេបានមកដល់ប្រទេសអូស្ត្រាលី ឬ
- ទទួលបាននូវប្រាក់ឧបត្ថម្ភសន្តិសុខសង្គម ប្រាក់សោធននិវត្តន៍សន្តិសុខសង្គម Parental Leave Pay ឬ Dad and Partner Pay ឬ Farm Household Allowance
- បានទទួលទិដ្ឋាការដែលអនុញ្ញាតឲ្យមានសិទ្ធិទទួលបាន Family Tax Benefit នៅមុនថ្ងៃទី1 ខែមករា ឆ្នាំ2019 ឬ

ប្រសិនបើអ្នកមានសិទ្ធិទទួលបាន Family Tax Benefit Part B អ្នកអាចទទួលបានប្រាក់ឧបត្ថម្ភនេះក្នុងខណៈដែលកំពុងបំពេញលក្ខខណ្ឌ Newly Arrived Resident’s Waiting Period ដើម្បីទទួលបាន Family Tax Benefit Part A។

## ប្រាក់ចិញ្ចឹមកូន និង Family Tax Benefit

ប្រសិនបើអ្នកទទួលបាន Family Tax Benefit ហើយនិងអ្នក ឬក៏ដៃគូរបស់អ្នកទទួលបាន ឬបង់ប្រាក់ចិញ្ចឹមកូន យើងនឹងពិនិត្យពិចារណាទៅលើប្រាក់ចិញ្ចឹមកូនរបស់អ្នក នៅពេលយើងគណនាប្រាក់ឧបត្ថម្ភ Family Tax Benefit របស់អ្នក។ ប្រសិនបើអ្នកចែករំលែកការថែទាំកូនរបស់អ្នក យើងនឹងគណនាភាគរយនៃការថែទាំ ហើយនិងប្រើប្រាស់ភាគរយនេះដើម្បីគណនាចំនួន Family Tax Benefit និងប្រាក់ចិញ្ចឹមកូនដែលអ្នកមានសិទ្ធិទទួលបាន។

## ការសុំប្រាក់ឧបត្ថម្ភ

អ្នកអាចជ្រើសរើសទទួល Family Tax Benefit ពីរសប្តាហ៍ម្តង ឬក៏ប្រាក់ឧបត្ថម្ភសរុបប្រចាំឆ្នាំ។ អ្នកត្រូវការដាក់ពាក្យសុំប្រាក់ឧបត្ថម្ភតាមអនឡាញ ឬក៏បំពេញទម្រង់សុំប្រាក់ឧបត្ថម្ភ។ ការសុំយកប្រាក់ឧបត្ថម្ភប្រចាំឆ្នាំត្រូវតែដាក់ពាក្យនៅក្នុងអំឡុងពេល 12ខែនៃដំណាច់ឆ្នាំសារពើពន្ធ។

អ្នកក៏ត្រូវការៈ

- ធ្វើឲ្យប្រាកដថាអ្នក និងដៃគូរបស់អ្នកដាក់ពាក្យទូទាត់ពន្ធដារនៅក្នុងអំឡុងពេល 12ខែនៃដំណាច់ឆ្នាំសារពើពន្ធ ហើយឲ្យ Australian Taxation Office (ក្រសួងពន្ធដារ) បញ្ជាក់ពីប្រាក់ចំណូលសម្រាប់អ្នក និងដៃគូរបស់អ្នក ឬក៏
- ប្រាប់យើងថាអ្នកមិនត្រូវការដាក់ពាក្យទូទាត់ពន្ធដារនៅក្នុងអំឡុងពេល 12ខែនៃដំណាច់ឆ្នាំសារពើពន្ធទេ។

ប្រសិនបើអ្នកជ្រើសរើសដើម្បីទទួល Family Tax Benefit 2សប្តាហ៍ម្តង អ្នកក៏ត្រូវប៉ាន់ស្មានប្រាក់ចំណូលប្រចាំឆ្នាំរបស់អ្នកដែរ។

## ការទូទាត់ Family Tax Benefit របស់អ្នក

មុនពេលដើមឆ្នាំសារពើពន្ធនីមួយៗដែលចាប់ផ្តើមនៅថ្ងៃទី1 ខែកក្កដា យើងសំណូមពរឲ្យអ្នកធ្វើការប៉ាន់ស្មានប្រាក់ចំណូលគ្រួសាររបស់អ្នក ដើម្បីឲ្យយើងអាចគណនចំនួន Family Tax Benefit ដើម្បីបើកជូនអ្នកនៅឆ្នាំសារពើពន្ធបន្ទាប់។

បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗដែលបញ្ចប់នៅថ្ងៃទី30 ខែមិថុនា យើងទូទាត់ប្រាក់ឧបត្ថម្ភរបស់អ្នក។ ការទូទាត់នេះមានន័យថា យើងប្រៀបធៀបចំនួន Family Tax Benefit ដែលយើងបានបើកជូនអ្នកដោយផ្អែកលើចំនួនប្រាក់ចំណូលដែលអ្នកបានប៉ាន់ស្មាននោះទៅនឹងចំនួនដែលអ្នកគួរទទួលបានដោយផ្អែកលើប្រាក់ចំណូលគ្រួសារពិតរបស់អ្នកសម្រាប់ឆ្នាំសារពើពន្ធនោះ។

ប្រសិនបើចំនួន Family Tax Benefit ដែលអ្នកបានទទួលមិនដូចគ្នានឹងចំនួនដែលអ្នកគួរទទួលបានទេ យើងនឹងកែសម្រួលប្រាក់ឧបត្ថម្ភរបស់អ្នក។

ប្រសិនបើអ្នកប៉ាន់ស្មានប្រាក់ចំណូលរបស់អ្នកខ្ពស់ អ្នកអាចបានទទួល Family Tax Benefit តិចជាងចំនួនដែលអ្នកមានសិទ្ធិទទួលបាន។ ប្រសិនបើអ្នកប៉ាន់ស្មានប្រាក់ចំណូលរបស់អ្នកទាប អ្នកអាចបានទទួលប្រាក់ឧបត្ថម្ភច្រើនពេក ហើយអ្នកអាចសងប្រាក់មកយើងវិញ។

សិទ្ធិទទួលបាន Family Tax Benefit Part A និង ប្រាក់ឧបត្ថម្ភបន្ថែមនៃ Family Tax Benefit Part B នឹងត្រូវធ្វើការវាយតម្លៃ និងបើកជូនអ្នក ប្រសិនបើអ្នកមានសិទ្ធិទទួលនៅក្នុងអំឡុងដំណើរការទូទាត់ នេះ។

## សម្រាប់ព័ត៌មានបន្ថែម

- សូមចូលទៅកាន់ **humanservices.gov.au/ftb** សម្រាប់ព័ត៌មានបន្ថែមជាភាសាអង់គ្លេស
- សូមចូលទៅកាន់ **humanservices.gov.au/yourlanguage** ជាទីកន្លែងដែលអ្នកអាន ស្តាប់ ឬទស្សនាព័ត៌មានជាភាសារបស់អ្នក។
- សូមហៅទូរស័ព្ទទៅកាន់លេខ **131 202** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពីប្រាក់ឧបត្ថម្ភ និងសេវារបស់ Centrelink។
- សូមហៅទូរស័ព្ទទៅសេវាបកប្រែ Translating and Interpreting Service (TIS National) តាមលេខ **131 450** ដើម្បីនិយាយជាមួយយើងជាភាសារបស់អ្នកអំពី Medicare ហើយនិងប្រាក់ឧបត្ថម្ភ និងសេវានានារបស់ Child Support (សេវាប្រមូល និងបើកប្រាក់ ចិញ្ចឹមកូន)។
- សូមអញ្ជើញមកកាន់មជ្ឈមណ្ឌលផ្តល់សេវា។

**កំណត់ចំណាំ៖** ការហៅទូរស័ព្ទចេញពីទូរស័ព្ទផ្ទះទៅកាន់លេខ ‘13’ ពីតំបន់ណាក៏ដោយនៅក្នុងប្រទេសអូស្ត្រាលីត្រូវបង់ថ្លៃក្នុងអត្រាថេរ។ អត្រានោះអាចខុសពីតម្លៃហៅចេញក្នុងតំបន់ ហើយក៏តម្លៃអាចខុសគ្នារវាងក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទនានាដែរ។ ការហៅទូរស័ព្ទទៅកាន់លេខ ‘1800’ ចេញពីទូរស័ព្ទផ្ទះគឺមិនគិតថ្លៃទេ។ ការហៅទូរស័ព្ទចេញពីទូរស័ព្ទសាធារណៈ និងទូរស័ព្ទដៃអាចដាក់កំណត់ពេល និងយកថ្លៃក្នុងអត្រាខ្ពស់ជាង។

## ការបដិសេធទំនួលខុសត្រូវ

ព័ត៌មានដែលមាននៅក្នុងឯកសារបោះពុម្ពនេះមានគោលបំណងសម្រាប់តែប្រើជាសៀវភៅណែនាំស្តីពីប្រាក់ឧបត្ថម្ភ និងសេវានានាប៉ុណ្ណោះ។ អ្នកត្រូវទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចិត្ត ប្រសិនបើអ្នកមានបំណងចង់ដាក់ពាក្យសុំប្រាក់ឧបត្ថម្ភ ហើយនិងដាក់ពាក្យសុំទាក់ទងនឹងស្ថានភាពពិសេសរបស់ អ្នក។

Australian Government
Department of Human Services

ENGLISH

# Family Tax Benefit

Family Tax Benefit is a two part payment that helps with the cost of raising children.

Family Tax Benefit Part A is paid for each child. The amount you get depends on your family's circumstances. If a child enters your care before they turn one, or you adopt a child of any age, you may get an increase to your Family Tax Benefit Part A. This is called Newborn Upfront Payment and Newborn Supplement.

Family Tax Benefit Part B gives extra help to single parents, non-parent carers (including grandparents) and couples with one main income earner. Your claim will be income tested and the amount you get will depend on the age of your youngest child.

In some situations, you may share the care of a child. If you are in this situation, you may still be eligible to get some Family Tax Benefit for the child if you care for them at least 35 per cent of the time.

## Eligibility

### Family Tax Benefit Part A

You may be eligible for Family Tax Benefit Part A if you care for a dependent child who is:

- younger than 15 years of age, or
- 16 to 19 years of age, and
    - undertaking full-time education in an approved course leading towards a year 12 or equivalent qualification with an acceptable study load, or
    - has been granted an exemption from education requirements.

If you are eligible for Family Tax Benefit Part A for a dependent child aged 16 to 19 years of age, it can be paid until the end of the calendar year in which they turn 19 years of age, if they continue in full-time secondary study.

### Family Tax Benefit Part B

If you are a member of a couple, you may be eligible for Family Tax Benefit Part B if you have care of a dependent child younger than 13 years of age.

If you are a single parent, grandparent or great-grandparent carer, you may be eligible for Family Tax Benefit Part B if you care for a child who is:

- younger than 16 years of age, or
- a full-time secondary student, up until the end of the calendar year in which they turn 18 years of age.

Home schooling for children 16 to 19 years of age does not satisfy study requirements for Family Tax Benefit.

### Immunisation requirements

2017-18 is the last year immunisation requirements are linked to the Family Tax Benefit Part A supplement.

From 1 July 2018, if your child does not meet the immunisation requirements, we may reduce your rate of Family Tax Benefit Part A.

**If you are receiving Family Tax Benefit Part A and an income support payment**
You need to make sure each child you are receiving Family Tax Benefit Part A for has a health check if they turn four on or after 1 July 2018. You need to tell us once the health check is complete. This must be done before the child's fifth birthday. If you do not tell us, we may reduce your Family Tax Benefit Part A payments.

We may reduce your payments for up to 26 fortnights. This is based on how long you got Family Tax Benefit Part A, and you or your partner got an income support payment.

## Residence requirements

To be eligible for Family Tax Benefit Part A and Part B, you must satisfy residence requirements.

You must be living in Australia and either:

- have Australian citizenship
- hold a permanent visa
- hold a Special Category Visa, or
- hold a certain temporary visa type, for example a Partner Provisional or Temporary Protection visa.

Your child must also meet the residence requirements or be living with you and you must continue to meet the residence requirements for as long as you get this payment.

If your permanent visa is granted on or after 1 January 2019, you must be living and physically residing in Australia for a period or periods that total at least one year before you can get Family Tax Benefit Part A.

You may not have to serve a Newly Arrived Resident's Waiting Period if you:

- are an Australian citizen, or
- arrived on a New Zealand passport (i.e., held or hold a Special Category visa), or
- are a refugee or former refugee, or
- hold or previously held a specific visa subclass, or
- are the partner of a refugee, former refugee or humanitarian migrant, and were the partner of that person at the time they arrived in Australia, or
- are in receipt of a social security benefit, social security pension, Parental Leave Pay, Dad and Partner Pay or Farm Household Allowance
- were granted a visa allowing eligibility for Family Tax Benefit before 1 January 2019, or

If you are eligible for Family Tax Benefit Part B, you can get this while you are serving the Newly Arrived Resident's Waiting Period for Family Tax Benefit Part A.

## Child support and Family Tax Benefit

If you get Family Tax Benefit and you or your partner get or pay child support, we will consider your child support when we calculate your Family Tax Benefit payment. If you share the care of your child, we will work out your percentage of care and use this to calculate how much Family Tax Benefit and child support you are eligible for.

## Claiming

You can choose to get Family Tax Benefit fortnightly or as an annual lump sum. You need to submit a claim online or complete a claim form. Annual lump sum claims must be submitted within 12 months of the end of the financial year.

You also need to:

- make sure you and your partner lodge tax returns within 12 months of the end of the financial year and have the Australian Taxation Office confirm the income for you and your partner, or
- tell us that you are not required to lodge a tax return within 12 months of the end of the financial year.

If you choose to get Family Tax Benefit fortnightly, you also need to estimate your income throughout the year.

## Balancing your Family Tax Benefit

Before the start of each financial year, which begins on 1 July, we ask you to estimate your family income so we can work out how much Family Tax Benefit to pay you over the next financial year.

After the end of each financial year, which finishes on 30 June, we balance your payment. This means we compare the amount of Family Tax Benefit we paid you based on your estimate, against how much you should have received, based on your actual family income for that financial year.

If the amount of Family Tax Benefit you received is not the same as the amount you should have received, your payments will be adjusted.

If you overestimated your income, you may have received less Family Tax Benefit than you were eligible for. If you underestimated your income, you may have been paid too much and may need to pay it back.

Your eligibility for Family Tax Benefit Part A and Family Tax Benefit Part B supplements will be assessed and paid, if eligible, during the balancing process.

## For more information

- go to **humanservices.gov.au/ftb** for more information in English
- go to **humanservices.gov.au/yourlanguage** where you can read, listen to or watch information in your language
- call **131 202** to speak with us in your language about Centrelink payments and services
- call the Translating and Interpreting Service (TIS National) on **131 450** to speak with us in your language about Medicare and Child Support payments and services
- visit a service centre.

**Note:** calls from your home phone to ‘13’ numbers from anywhere in Australia are charged at a fixed rate. That rate may vary from the price of a local call and may also vary between telephone service providers. Calls to ‘1800’ numbers from your home phone are free. Calls from public and mobile phones may be timed and charged at a higher rate.

## Disclaimer

The information contained in this publication is intended only as a guide to payments and services. It’s your responsibility to decide if you wish to apply for a payment and to make an application with regard to your particular circumstances.